# សេវាធានារ៉ាប់រង

MCCSA
Multicultural Communities Council of South Australia

គ្រោះធម្មជាតិអាចធ្វើឲ្យផ្ទះនិងរបស់របរក្នុងផ្ទះខូចខាតឬខូចទាំងស្រុង។ គេគួរជាវសេវាធានារ៉ាប់រងសម្រាប់ ៖

- ផ្ទះ ឬអាគារ
- របស់របរក្នុងផ្ទះ( សម្រាប់ម្ចាស់ផ្ទះនិងអ្នកជួល )។ ប្រសិនបើអ្នកជួលផ្ទះគេ ធ្វើយ៉ាងណាឲ្យក្រុមហ៊ុនធានារ៉ាប់រងរបស់អ្នកដឹងដូច្នោះផង។
- សេវាធានារ៉ាប់រងរថយន្ត។ មានតែសេវាធានារ៉ាប់រងពេញលក្ខណៈទេ( សងទាំងសងខាង ) ដែលមានការរ៉ាប់រងប្រសិនបើរថយន្តមានការខូចខាតដោយសារគ្រោះធម្មជាតិ ដូចជាភ្លើងឆេះព្រៃ ឬទឹកជំនន់ជាដើម។

ការយល់អំពីឧបត្តិហេតុនិងការខូចខាតអ្វីខ្លះដែលមានការរ៉ាប់រងពីក្រុមហ៊ុនធានារ៉ារង អាចជួយឲ្យអ្នកទិញសេវាធានារ៉ាប់រងដែលត្រូវ សម្រាប់ផ្ទះរបស់អ្នក។

ដើម្បីដឹងថាតើអ្នករស់នៅក្នុងតំបន់ដែលងាយមានគ្រោះមហន្តរាយឬអត់ សូមទាក់ទងសាលាក្រុងមូលដ្ឋានរបស់អ្នក។

ចូរសុំឲ្យគេមើលក្នុងប្រព័ន្ធរបស់គេថាតើផ្ទះរបស់អ្នកមានបញ្ហាដែរឬទេចំពោះទឹកជំនន់ កំណត់ត្រាសារតារអំពីទឹកជំនន់ និងហានិភ័យអំពីភ្លើងឆេះព្រៃ។

ទោះបីសេវាធានារ៉ាប់រងផ្ទះនិងរបស់របរក្នុងផ្ទះមានរ៉ាប់រងចំពោះការខូចខាតដែលបង្កដោយអគ្គីភ័យ រួមទាំងភ្លើងឆេះព្រៃនិងខ្យល់ព្យុះ ប៉ុន្តែមិនមែនគ្រប់សេវារ៉ាប់រងទាំងអស់រ៉ាប់រងលើការខូចខាតបណ្តាលមកពីទឹកជំនន់ទេ។ សូមសួរគេថាតើអ្នកត្រូវការឲ្យគេបញ្ចូលទៅទទួលការរ៉ាប់រងលើទឹកជំនន់ឬអ្វីផ្សេងទៀតដែរឬអត់។

សូមពិនិត្យមើលថាតើសេវាធានារ៉ាប់រងរបស់អ្នកមានបច្ចុប្បន្នភាព និងមានផ្តល់ការរ៉ាប់រងលើទឹកជំនន់ដែរឬអត់។ សូមកុំរង់ចាំទាល់តែអ្នកបាត់អ្វីៗទាំងអស់ហើយបានទៅរកមើលថាសេវាធានារ៉ាប់រងរបស់អ្នករ៉ាប់រងលើអ្វីខ្លះ។

សារនេះផ្តល់ជូនលោកអ្នកដោយ Multicultural Communities Council of South Australia
ជាផ្នែកមួយនៃគំរោងកាត់បន្ថយហានិភ័យពីគ្រោះមហន្តរាយ ឧបត្ថមថវិកាដោយរដ្ឋាភិបាលសហព័ន្ធអូស្ត្រាលី
និងរដ្ឋាភិបាលនៃរដ្ឋអូស្ត្រាលីខាងត្បូង។

**Multicultural Communities Council of South Australia**
113 Gilbert Street, Adelaide SA 5000
**PHONE** (08) 8345 5266
**E** mccsa@mccsa.org.au
**www.mccsa.org.au**